01673091



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Jun-21, 15:43
CMS/CFO: Sann Rada

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រ៊ីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Maureen Harding CLARK
ចៅក្រម យ៉ា ណារិន

| | |
|---|---|
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២១ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សម្ងាត់ |

---

# សេចក្តីសម្រេចលើសំណើសុំធ្វើជាសិទ្ធិវ័ន្តដើម្បីបន្តបណ្តឹងរដ្ឋប្បវេណី

---

**សហព្រះរាជអាជ្ញា**

ជា លាង

Brenda HOLLIS

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Megan HIRST

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ទី ស្រ៊ីនណា

**ជនជាប់ចោទ**

ខៀវ សំផន

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

គង់ សំអុន

Anta GUISSÉ

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល")

**បានទទួល** សំណើសុំ"ឱ្យសិទ្ធិវ័ន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលមរណភាព បន្តទាមទារសំណងរដ្ឋប្បវេណី"[1] ដែលបានដាក់តាំងពីដំបូងជាសាធារណៈដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទី ស្រ៊ីនណា នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០២០ ("សំណើសុំ" និង"មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី") បានជូនដំណឹងអង្គជំនុំជម្រះតុលាការកំពូលអំពីមរណភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឈុន សាម៉ន មានលេខសំគាល់ (09-VU-04216) ដែលបានទទួលមរណភាពនៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៨ និងស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលអនុញ្ញាតប្រពន្ធរបស់គាត់ឈ្មោះ មាន អេង បន្តទាមទារសំណងរដ្ឋប្បវេណីជំនួសប្តីរបស់គាត់

**កត់សម្គាល់**លើឧបសម្ព័ន្ធសម្ងាត់គាំទ្រសំណើនេះ ដែលបញ្ជាក់នូវទំនាក់ទំនងរវាង មាន អេង ជាមួយនឹង ឈុន សាម៉ន គឺជាសហព័ទ្ធ (i) លិខិតអះអាងរបស់ មាន អេង ក្នុងការបន្តសិទ្ធិវ័ន្តជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០២០[2] (ii) សំបុត្រមរណភាពរបស់ ឈុន សាម៉ន ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៨[3] (iii) អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ[4] និង (iv) សៀវភៅគ្រួសាររបស់ មាន អេង[5] (ជារួម "ឧបសម្ព័ន្ធ")

**កត់សម្គាល់**ថា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើសុំឱ្យដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញពីសាធារណៈទៅជាសម្ងាត់នៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២១[6]

**កត់សម្គាល់**ថា សហព្រះរាជអាជ្ញា និង ខៀវ សំផន ពុំបានដាក់សារណាតបទៅនឹងសំណើនេះ

---

[1] ឯកសារលេខ F57។

[2] លិខិតអះអាងរបស់ មាន អេង អំពីសន្តតិកម្មជាដើមបណ្តឹងរដ្ឋប្បវេណី ឯកសារលេខ F57.1 ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០២០។

[3] សំបុត្រមរណភាពរបស់ ឈុន សាម៉ន ឯកសារលេខ F57.2 ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៨។

[4] អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ មាន អេង ឯកសារលេខ F57.3។

[5] សៀវភៅគ្រួសាររបស់ មាន អេង ឯកសារលេខ F57.4។

[6] *សូមមើល* ឯកសារលេខ E-5/corr-1 ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២១។

**ពិចារណា**ថា នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេតក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស ដែលបច្ចុប្បន្នជាសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក. បានប្រកាស និងទទួលស្គាល់ ឈុន សាម៉ន ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធី[7]

**ពិចារណាឃើញ**ថា វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. ពុំបានចែងជាក់លាក់អំពីទម្រង់បែបបទត្រូវអនុញ្ញាតតាមក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ បានទទួលមរណភាព នៅមុនពេលកិច្ចដំណើរការនីតិវិធីលើរឿងក្តីព្រហ្មទណ្ឌត្រូវបានបញ្ចប់

**ពិចារណាឃើញ**ថា ច្បាប់កម្ពុជាបានអនុញ្ញាតឱ្យសិទ្ធិវ័ន្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលមរណភាព ផ្តើមធ្វើ ឬបន្តបានក្នុងការទាមទារសំណងរដ្ឋប្បវេណីជំនួស[8]

**ពិចារណាឃើញ**ថា វិធានពុំបានចែងអំពីការផ្តល់សំណងជារូបិយវត្ថុដល់ជនរងគ្រោះនៃបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានសម្រេចដាក់ពិរុទ្ធភាព

**ពិចារណាឃើញ**ថា វិធានបានចែងត្រឹមតែ“សំណងសមូហភាព និងផ្លូវចិត្ត”[9]

**ពិចារណាឃើញ**ថា ដើម្បីទទួលបានសំណងផ្លូវចិត្ត សិទ្ធិវ័ន្តដែលមានបំណងទាមទារសំណងជំនួសមរណជនដែលជាជនរងគ្រោះ ត្រូវបង្ហាញថា ជនរងគ្រោះបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[10]

**រំឭក**ថា ឈុន សាម៉ន គឺជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលស្គាល់ក្នុងរឿងក្តីនេះ

---

[7] ដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តស្វាយរៀង សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស. ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០ ទំព័រ ១១ ដល់ ១២។

[8] មាត្រា ១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ *សូមមើល* សេចក្តីសម្រេចលើសំណើពាក់ព័ន្ធទៅនឹងមរណភាពនៃដើមបណ្តឹងរដ្ឋប្បវេណី សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ដ. ឯកសារលេខ E2/5/3 ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១០។

[9] វិធាន ២៣(១)(ខ) នៃវិធានផ្ទៃក្នុង។

[10] សេចក្តីសម្រេចស្តីពីសន្តតិកម្ម ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ១១។

**យល់ឃើញ**ថា ឧបសម្ព័ន្ធបានបង្ហាញថា ឈុន សាម៉ន បានទទួលមរណភាព[11]

**កត់សម្គាល់ឃើញ**ថា មាន អេង ស្នើសុំការអនុញ្ញាតធ្វើជាសិទ្ធិវ័ន្តពីមរណជន ឈុន សាម៉ន និង អះអាងថា គាត់ត្រូវបានស្នើដោយ ឈុន សាម៉ន ឱ្យបន្តការទាមទារសំណងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ[12]

**យល់ឃើញ**ថា មាន អេង ពុំបានផ្ដល់លិខិតអាពាហ៍ពិពាហ៍ដែលបញ្ជាក់ថា គាត់បានរៀបការត្រឹមត្រូវតាមច្បាប់ជាមួយនឹងមរណជនស្របតាមច្បាប់របស់កម្ពុជា និងទទួលបានឋានៈជាសិទ្ធិវ័ន្តស្របច្បាប់ស្របតាមក្រមរដ្ឋប្បវេណីរបស់កម្ពុជា

**ពិចារណាឃើញ**ថា មាន អេង បានផ្ដល់សៀវភៅគ្រួសារចុះហត្ថលេខា និងបោះត្រាដោយស្នងការនគរបាលក្នុងឃុំរបស់គាត់ដែលបានបញ្ជាក់ថា មាន អេង ជាមេគ្រួសារ និងជាប្រពន្ធរបស់ ឈុន សាម៉ន និងថា ពួកគាត់មានកូនប្រាំនាក់[13]

**ពិចារណាឃើញ**ថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីមុនៗ ត្រូវបានអនុញ្ញាតជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងឋានៈជា“ជនរងគ្រោះមិនផ្ទាល់” ផ្អែកលើចំណងនៃក្ដីស្រលាញ់ដែលអាចសន្និដ្ឋានបាន ឬការដែលស្ថិតក្នុងបន្ទុក[14]

**យល់ឃើញ**ថា បើទោះបីជានត្ថិភាពនៃភស្តុតាងបង្ហាញពីការរៀបអាពាហ៍ពិពាហ៍ សៀវភៅគ្រួសាររបស់ មាន អេង បង្ហាញក្នុងកម្រិតអប្បបរមាអំពីទំនាក់ទំនងយូរអង្វែងជាមួយ ឈុន សាម៉ន និង មាន អេង ដូចនេះបានបង្ហាញពីចំណងនៃក្ដីស្រលាញ់ ឬការស្ថិតក្នុងបន្ទុករវាងអ្នកទាំងពីរ

**ហេតុដូច្នេះ យល់ឃើញ**ថា សម្រាប់គោលបំណងតែមួយគត់នៃការទាមទារសំណងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ និងពុំមែនជាការប្រកាសអំពីការទទួលសិទ្ធិវ័ន្តស្របតាមអត្ថន័យនៃក្រមរដ្ឋប្បវេណី

---

[11] លិខិតមរណភាពរបស់ ឈុន សាម៉ន ឯកសារលេខ F57.2 ថ្ងៃទី ២៨ ខែ សីហា ឆ្នា ២០១៨។

[12] លិខិតអះអាងក្នុងការបន្តសិទ្ធិវ័ន្តជាដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារលេខ F57.1 ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០២០។ *សូមមើល* សៀវភៅគ្រួសាររបស់ មាន អេង ឯកសារលេខ F57.4។ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឯកសារលេខ F57.3។

[13] សៀវភៅគ្រួសាររបស់ មាន អេង ឯកសារលេខ F57.4។

[14] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០១ កថាខណ្ឌ ៦៥០។ សាលដីកាសំណុំរឿង ០០១ កថាខណ្ឌ ៤១៦ ដល់ ៤១៩, ៤២២, ៤៣៦, ៤៤៥ ដល់ ៤៥០, ៥៥៨ ដល់ ៥៦៣។

កម្ពុជា អង្គជំនុំជម្រះតុលាការកំពូលត្រៀមលក្ខណៈទទួលយក មាន អេង ជាសិទ្ធិវ័ន្តបន្តការទាមទារសំណងរបស់ ឈុន សាម៉ន

ដោយអនុលោមតាមវិធាន ២ និង ២៣ នៃវិធានផ្ទៃក្នុង និងមាត្រា ១២ នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.

**អាស្រ័យហេតុនេះ÷**

**សម្រេចទទួលយក**សំណើនេះ និង

**សម្រេច**ថា មាន អេង ត្រូវបានអនុញ្ញាតឱ្យបន្តការទាមទាររបស់ ឈុន សាម៉ន លេខសម្គាល់ (09-VU-04216) ក្នុងបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក.។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២១

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ឹម**